# ទំព័រអំពីកម្ពុជានិងសូចនាករសំខាន់ៗ

CAMBODIA



ចំនួនប្រជាជន 14,9 លាននាក់

កំនើនប្រជាជន 1,8 ភាគរយ

ផសស (PPP, int'l US$) 37,1ពាន់លាន

ផសសក្នុងពលរដ្ឋម្នាក់ (PPP, int'l US$) 2,494

ផ្ទៃដី 181,040 គីឡូម៉ែតការ៉េ

រាជធានី ភ្នំពេញ

Source: World Development Indicators

## ខ្លឹមសារសង្ខេប

**សេដ្ឋកិច្ចកម្ពុជាមានភាពធន់ ទប់ទល់បាននឹងសម្ពាធក្នុងស្រុក ថែមទាំងបានរក្សាកំណើនខ្ពស់ទៀតផង ។** កំណើនសេដ្ឋកិច្ចរបស់កម្ពុជា មានភាពធន់ ទប់ទល់បានយ៉ាងល្អ ទោះបីជាមានឥទ្ធិពលអវិជ្ជមានដោយសារភាពមិនប្រាកដប្រជាផ្នែកនយោបាយ និង ភាពរឹករវ ផ្នែកពលកម្មក៏ដោយ នៅពេលអតិផរណាកើនឡើងបន្តិច ។ កំណើនសេដ្ឋកិច្ចត្រូវប៉ាន់ស្មានថា បាន ប្រហែល ៧,៤ភាគរយនៅឆ្នាំ2013 នាំមុខដោយការនាំចេញសម្លៀកបំពាក់ ដែលកំពុងបន្ថែមល្បឿន និងផ្នែកទេសចរបន្តការកើនឡើង។ កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១៤ ត្រូវបានព្យាករថានឹងមានកំណើន 7,2 ភាគរយ ដោយផ្អែកលើឡើងការបន្តងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក ការត្រលប់មកវិញនៃ ស្ថិរភាព នយោបាយ និងការរំពឹងថានឹងមានជំនឿជឿជាក់ឡើងវិញ។ វិស័យធនាគារកំពុងរីកចម្រើន ជាមួយនឹងភាពស៊ីជំម្រៅផ្នែកហិរញ្ញវត្ថុនៅតែបន្តកើតមានឡើង។ ទោះជាការប្រមូលពន្ធក្នុងស្រុកមានការកើនឡើងក្នុងកំរិតទាប ប៉ុន្តែស្ថានភាពសារពើពន្ធនៅតែប្រកបដោយចីរភាព។ យ៉ាងណាក៏ដោយភាពរឹករវផ្នែកពលកម្មសារជាថ្មីទៀត និងឥទ្ធិពលអវិជ្ជមានដោយសារការកាត់បន្ថយការអនុវត្តគោលនយោបាយជំរុញសេដ្ឋកិច្ចនៃធនាគារសហព័ន្ធអាមេរិក អាចបង្កជាហានិភ័យ។

## ស្ថានភាពអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ

**សេដ្ឋកិច្ចកម្ពុជាមានភាពធន់ ទប់ទល់បាននឹងសម្ពាធនយោបាយនិងសង្គមក្នុងស្រុកថែមទាំងបានរក្សាកំណើនខ្ពស់ទៀតផង។** សេដ្ឋកិច្ចកម្ពុជាបានដំណើរការល្អជាងការគ្រោងទុកទោះជាមានការមិនប្រាកដប្រជាផ្នែកនយោបាយ និងភាពរឹករវផ្នែកពលកម្មក៏ដោយ។សំណាងល្អ ទឹកជំនន់ឆ្នាំ2013បានធ្វើអោយខូចខាតផលិតផលស្រូវតិច ។ ជាមួយនឹងការង្កើនល្បឿននៃការនាំចេញសម្លៀកបំពាក់ និងបន្តកំណើនផ្នែកទេសចរ កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ2013 ត្រូវប៉ាន់ប្រមាណ

ថានឹងបាន7,4%។ ទស្សនៈវិស័យថែរក្សាបាន កំណើនខ្ពស់ នៅតែមានអំនោយផល កំណើន ផលិតផលក្នុងស្រុកសរុបពិតក្នុងឆ្នាំ 2014 ត្រូវ ប៉ាន់ប្រមាណថានឹងបាន7,2% ដោយសារការ ត្រលប់មកវិញនៃស្ថិរភាពនយោបាយ ការរំពឹងថា នឹងមានជំនឿជឿជាក់ឡើងវិញ និងការងើបឡើង វិញនៃសេដ្ឋកិច្ចរបស់ប្រទេសអភិវឌ្ឍនានា។ យ៉ាង ណាក៏ដោយភាពរឹករវផ្នែកពលកម្មសារជាថ្មីទៀត និងការកាត់បន្ថយការអនុវត្តគោលនយោបាយ ជំរុញសេដ្ឋកិច្ចនៃធនាគារសហព័ន្ធអាមេរិក អាច បង្កជាហានិភ័យ។ ឥទ្ធិពលអវិជ្ជមានជាដំបូងនៃ ការកាត់បន្ថយការអនុវត្តគោលនយោបាយជំរុញ សេដ្ឋកិច្ច បណ្តាលអោយមានការធ្លាក់ថ្លៃ នៃរូបិយប័ណ្ណក្នុងស្រុកដែលប្រទេសកំពុង អភិវឌ្ឍន៍ភាគច្រើនកំពុងជួបប្រទះ ជាទូទៅនឹងធ្វើ ឲ្យការនាំចេញរបស់ពួកគេមានភាពប្រកួតប្រជែង កាន់តែខ្ពស់។ ទោះជាយ៉ាងណាក្តី សភាពការណ៍ នេះមានលក្ខណៈផ្ទុយគ្នាក្នុងករណីនៃការនាំចេញ របស់កម្ពុជា ដោយសារតែសេដ្ឋកិច្ចកម្ពុជាចរាចរ ប្រាក់ដុល្លារយ៉ាងខ្ពស់។

**វិស័យទូទាត់ក្រៅប្រទេសបានប្រសើរជាងមុន ក្នុង បរិបទដែលលំហូរវិនិយោគផ្ទាល់ពីបរទេសសំរួល ល្បឿន ។** ដោយសារតែតំរូវការក្នុងស្រុកបាន បន្ថយល្បឿន ការនាំចូលមានកំណើនយឺត ពេលដែលការនាំចេញបានបង្កើនល្បឿន។ នេះ បានរួមចំណែកបានធ្វើអោយ ឱនភាពគណនី ចរន្តបានរួមតូច (មិនគិតការផ្ទេរផ្លូវការ) ថយមក ត្រឹម 9,4ភាគរយនៃ ផសសនៅឆ្នាំ2013 បើធៀប នឹង10,1 ភាគរយនៃ ផសសនៅឆ្នាំ2012។ លំហូរ វិនិយោគផ្ទាល់បរទេសនៅតែបន្តប៉ុន្តែដោយសារ តែមានភាពមិនប្រាកដប្រជាផ្នែកនយោបាយ លំ ហូរវិនិយោគផ្ទាល់បរទេសនៅឆ្នាំ2013 ត្រូវប៉ាន់ ប្រមាណថាទាបជាងកំរិតខ្ពស់បំផុតក្នុងឆ្នាំ2012។ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងបន្តិច ដល់ប្រមាណ 3,6ពាន់លានដុល្លារ អាមេរិក ឬ ដែលអាចធានា ការនាំចូលបាន 3,8ខែក្នុងឆ្នាំ 2013 បើប្រៀបធៀបនឹង 3,5ពាន់លានដុល្លាអាមេ រិកក្នុងឆ្នាំ2012។

**អតិផរណាកើនឡើងបន្តិច** ។នៅពេលដែលថ្លៃ ទំនិញឧបភោគបរិភោគដែលជាតម្រូវការជាចំបាច់ នៅតែមានស្ថិរភាព សម្ពាធអតិផរណាកំពុងកើន បន្តិចម្តងៗដោយសារ ការងើបឡើងថ្មីៗនេះ នៃ តម្លៃមុខទំនិញម្ហូបអាហារ មួយចំនួន។ អតិផរណា កើនដល់ ៤,៧ ភាគរយ នៅចុងឆ្នាំ2013 បើធៀប នឹងចុងឆ្នាំ2012ដែលពេលនោះវានៅមានកំរិតតែ ២,៥ភាគរយប៉ុណ្ណោះ។ អតិផរណាត្រូវបានព្យាករ ថា នៅក្នុងកម្រិតពាក់ កណ្តាលលេខមួយខ្ទង់ក្នុង កំឡុងដំណាក់កាលខ្លី។

**កំណើនប្រាក់បញ្ញើ របស់វិស័យឯកជនមានល្បឿន យឺតជាងមុន នៅពេលដែលកំណើននៃឥណទាន នៅតែខ្ពស់។** ឥទ្ធិពលអវិជ្ជមាននៃភាពមិនប្រាកដ ប្រជាផ្នែកនយោបាយមកលើជំនឿជឿជាក់ ធ្វើអោយកំណើនប្រាក់បញ្ញើរបស់វិស័យឯកជន យឺតជាងមុនច្រើន។ កំណើនប្រាក់បញ្ញើរបស់ វិស័យឯកជននៅចុងឆ្នាំ2013មាន 14,2ភាគរយ ថយចុះពី 25,2ភាគរយ នៅនៅចុងឆ្នាំ2012។ ផ្ទុយទៅវិញកំណើននៃឥណទានសំរាប់វិស័យឯក ជននៅតែខ្លាំងក្លា កើនឡើង26,6ភាគរយ នៅឆ្នាំ 2013 ថយចុះតិចតួចពីកំណើន28,0ភាគរយក្នុង ឆ្នាំ2012។ ការណ៍នេះបង្កើនហានិភ័យនៃការមាន បញ្ហាសាច់ប្រាក់ងាយស្រួលនៅក្នុងប្រព័ន្ធធនាគា រ។ អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើបន្តកើន ឡើង គឺពី80 ភាគរយ នៅចុងឆ្នាំ 2012 ដល់ 90 ភាគរយនៅចុងឆ្នាំ 2013។ កំណើនរូបិយវត្ថុទូទៅ

ក៏បន្ថយល្បឿន ដោយសារតែប្រាក់បញ្ញើជារូបិយប័ណ្ណកើនឡើងយឺត គឺមានកំណើន14,6ភាគរយនៅចុងឆ្នាំ2013 ឬ ដល់6,7ពាន់លានដុល្លារអាមេរិក បើប្រៀបធៀបនឹងកំណើន20,9 ភាគរយនៅចុងឆ្នាំ2012 ឬ 5,9ពាន់ លានដុល្លារអាមេរិក។

**លំហូរសារពើពន្ធប្រសើរឡើងថែមទោះបីជាកំណើនចំណូលក្នុងស្រុករបស់រដ្ឋាភិបាលមិនសូវខ្លាំងក្លា ។** បន្ទាប់ពី ការកើនឡើងយ៉ាងគំហុកក្នុងឆ្នាំ ២០១២ កំណើនចំណូលក្នុងស្រុកមិនសូវខ្លាំងក្លា កើនចំនួន៨ភាគរយ ក្នុងឆ្នាំ២០១៣ ប្រៀបធៀបនឹង ២៧ភាគរយក្នុងឆ្នាំ ២០១២ដោយសារកំណើននៃចំណូលពីការនាំចូល នឹងចំណូលមិនមែនសារពើពន្ធយឺត។ក្នុងឆ្នាំ២០១៣ចំណូល ក្នុងស្រុកត្រូវបានប៉ាន់ប្រមាណថានឹងមាន១៤,៨ភាគរយនៃផសស ទាបជាងចំណូលខ្ពស់បំផុត គឺប្រមាណ១៥,៣ភាគរយនៃផសស ដែលប្រមូលបាននៅឆ្នាំ ២០១២។ ចំណាយសាធារណៈត្រូវបានរឹតត្បិត ក្នុងរង្វង់២១,៣ភាគរយនៃផសស ក្នុងឆ្នាំ២០១៣ ប្រហាក់ប្រហែលកំរិតនៅឆ្នាំ ២០១២ដែរ។ឱនភាពសារពើពន្ធ (រួមទាំងជំនួយ ឥតសំណង)ក្នុងឆ្នាំ២០១៣ត្រូវបានប៉ាន់ប្រមាណថាមាន ៣,៩ភាគរយនៃផសស លើសឆ្នាំ ២០១២បន្តិច ដែលមាន៣,៣ភាគរយនៃផសស ត្រូវបានផ្តល់ហិរញ្ញប្បទានលើសលប់ពីបរទេស ។ ទន្ទឹមគ្នា នេះប្រាក់សន្សំរបស់រដ្ឋាភិបាលកើនឡើងដល់៧៦០លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ពី៦៩០ លានដុល្លារអាមេរិកពីឆ្នាំ ២០១២។

**ចំណាត់ថ្នាក់ ភាពតានតឹងនៃបំណុលរបស់កម្ពុជានៅតែទាប។**ការវិភាគ និរន្តភាពបំណុល(DSA) ដែលធ្វើឡើង រួមគ្នារវាង ធានាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តជាតិនៅឆ្នាំ2013 បង្ហាញថាចំណាត់ថ្នាក់ភាពតានតឹងនៃបំណុលនៅតែទាបជាមួយ នឹងសូចនាករបន្ទុកបំណុលនានា ត្រូវបានគ្រោង ថាទាបជាងកម្រិតគោល។ ស្រដៀងនឹងការវាយតំលៃកាលពីឆ្នាំ2012ដែរ លទ្ធផលបង្ហាញថានិរន្តរនៃបំណុលនៅតែមានភាពផុយស្រួយចំពោះ កំណើនសេដ្ឋកិច្ច ការនាំចេញ និងវិបត្តិសារពើពន្ធ ដែលសឲ្យឃើញតម្រូវការកំណែទម្រង់រចនាសម្ព័ន្ធជាបន្ត ដើម្បីធ្វើពិពិធកម្មកំណើន និងកែលម្អការប្រមូលចំណូល។ ទំហំបំណុលបរទេស របស់ប្រទេសកម្ពុជា (រួមទាំងបំណុលកកស្ទះ) មានចំនួន 4,5ពាន់លានដុល្លារអាមេរិក ឬ 32ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅចុងឆ្នាំ2012 ។

**ទស្សនៈវិស័យនិងភាពប្រឈមដែលកើតឡើង**

**ចំណាត់ការអោយបានសមស្របចំពោះសំពាធខាងក្នុងនិងទប់ទល់ឥទ្ធិពលអវិជ្ជមាន នៃការកាត់បន្ថយការអនុវត្តគោលនយោបាយជំរុញសេដ្ឋកិច្ចនៃធនាគារសហព័ន្ធអាមេរិក ដើម្បីគាំពារ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។** ដោះស្រាយភាពរំជើប រំជួលខាងផ្នែកពលកម្ម ដោយចរចារប្រាក់បៀវត្សប្រកបដោយជោគជ័យផ្តល់ផលប្រយោជន៍ទាំងសងខាងសំរាប់ និយោជិក និងក្រុមហ៊ុន។ ដូចគ្នាដែរកែលំអបន្ថែមការគ្រប់គ្រងធនាគារ នឹងពង្រឹងថែមទៀត នៃវិស័យហិរញ្ញវត្ថុ។ ពង្រឹងសមាហរណកម្មក្នុងតំបន់ និងអនុញ្ញាតអោយកម្ពុជាទទួលផលប្រយោជន៍ច្រើនទៀតពីការលូតលាស់ដ៏ខ្លាំងក្លាទូទាំងតំបន់នៃប្រទេសនានាក្នុងសហគមប្រជាជាតិអាស៊ីអាគ្នេយ៍។

# ប្រទេសកម្ពុជា: សូចនាករសំខាន់ៗ

| | 2011<br>Year | 2012<br>Year | 2013e<br>Year | 2014p<br>Year | 2015f<br>Year |
|---|---|---|---|---|---|
| **លទ្ធផល ការងារ និងថ្លៃ** | | | | | |
| ផសស ពិត (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 7.1 | 7.3 | 7.4 | 7.2 | 7.0 |
| តម្រូវការក្នុងស្រុក (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 1.0 | 11.9 | 8.5 | 9.7 | 10.2 |
| សន្ទស្សន៍ផលិតកម្មឧស្សាហកម្ម (2000=100) | 300.8 | 315.9 | 341.1 | 368.4 | 396.1 |
| (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 14.5 | 5.0 | 8.0 | 8.0 | 7.5 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 4.9 | 2.5 | 4.7 | 5.0 | 5.5 |
| **វិស័យសាធារណៈ** | | | | | |
| ចំណូលរដ្ឋាភិបាល (% នៃ ផសស) | 13.2 | 15.3 | 14.8 | 15.0 | 15.0 |
| ចំណាយរដ្ឋាភិបាល (% នៃ ផសស) | 22.8 | 21.0 | 21.3 | 20.3 | 20.0 |
| តុល្យការរដ្ឋាភិបាលមិនបូករួមទាំងជំនួយឥតសំណង(% នៃ ផសស) | -9.6 | -5.7 | -6.5 | -5.3 | -5.0 |
| តុល្យការរដ្ឋាភិបាលបូករួមទាំងជំនួយឥតសំណង(% នៃ ផសស) | -4,6 | -3,3 | -3,9 | -3,2 | -3,5 |
| **ពាណិជ្ជកម្មក្រៅប្រទេស ជញ្ជីងទូទាត់ និង បំណុលបរទេស** | | | | | |
| តុល្យភាពពាណិជ្ជកម្ម (លានដុល្លារអាមេរិក) | -1,490 | -1,949.2 | -1,983.9 | -2,096.2 | -2,508.9 |
| ទំនិញនាំចេញ (លានដុល្លារអាមេរិក) | 5,219.5 | 6,015.7 | 6,777.5 | 7,979.4 | 9,229.2 |
| (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 34.4 | 15.3 | 12.7 | 17.7 | 15.7 |
| ទំនិញនាំចេញសំខាន់ៗ (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) 1/ | 31.7 | 7.0 | 17.6 | 17.5 | 15.5 |
| ទំនិញនាំចូល (លានដុល្លារអាមេរិក) | 6,709.5 | 7,964.9 | 8,761.4 | 10,075.6 | 11,738.1 |
| (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 22.7 | 18.7 | 10.0 | 15.0 | 16.5 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិក) 2/ | -1,014.9 | -1,436.6 | -1,450.9 | -1,620.1 | -1,824.9 |
| (% នៃ ផសស) | -7.9 | -10.1 | -9.4 | -9.7 | -10.0 |
| ការវិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក) | 785.4 | 1,410.2 | 1,200.0 | 1,450.0 | 1,710.0 |
| បំណុលបរទេស (លានដុល្លារអាមេរិក) | 3,840.8 | 4,486.0 | 5,052.0 | 5,559.4 | 5,948.7 |
| (% នៃ ផសស) | 29.9 | 31.6 | 32.6 | 33.2 | 32.5 |
| បំណុលរយៈពេលខ្លី (លានដុល្លារអាមេរិក) | - | - | - | - | - |
| អនុបាតសេវាបំណុល(% នាំចេញទំនិញនិងសេវាកម្ម) | 1.2 | 1.2 | 1.3 | 1.5 | 1.5 |
| ប្រាក់បំរុងបរទេសដុល (លានដុល្លារអាមេរិក) | 3,031.6 | 3,463.0 | 3,642.5 | 3,879.3 | 4,267.2 |
| (ចំនួនខែនាំចូលទំនិញនិងសេវាកម្ម) | 3.4 | 3.1 | 3.8 | 3.5 | 3.4 |
| **ទីផ្សារហិរញ្ញវត្ថុ** | | | | | |
| ឥណទានក្នុងស្រុក (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 37.3 | 29.6 | 28.5 | 26.0 | 25.2 |
| អត្រាប្តូរប្រាក់រយៈពេលខ្លី (ក្នុងមួយឆ្នាំ) | 15.0 | 13.7 | 13.0 | 13.0 | 12.8 |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លាអាមេរិកចុងគ្រា) | 4,039 | 3,995 | 4,000 | 4,065 | 4,076 |
| អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត(2005=100) | 124.8 | 128.6 | 131.0 | 132.9 | 134.7 |
| (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 1.9 | 3.0 | 1.8 | 1.5 | 1.3 |
| កំណត់ចំណាំ:ផសស ជាក់ស្តែង (គិតជាលានដុល្លារអាមេរិក) | 12,828 | 14,196 | 15,491 | 16,722 | 18,291 |

ប្រភព: ប្រភពទិន្នន័យជាតិ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិនិងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

e = ប៉ាន់ស្មាន

f = ព្យាករណ៍

p = ព្យាករណ៍(គណនា)

1/ វិស័យកាត់ដេរ

2/ មិនរាប់បញ្ចូលប្រាក់បង្វែរផ្លូវការ